ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៤៣ សករបយ.  រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយគិតជាមធ្យមចំនួន១២សប្តាហ៍បន្តបន្ទាប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល ឬសេចក្តីត្រូវការជាចាំបាច់ក្នុងផលិតកម្ម ឬសេវាកម្ម ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ អាចបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយយកចំនួនជាមធ្យម១២សប្តាហ៍បន្តបន្ទាប់មកគិត ។

**ប្រការ២.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលចង់បែងចែកម៉ោងធ្វើការតាមរបៀបខាងលើនេះ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :-

-ថិរវេលាធ្វើការគិតជាមធ្យមក្នុងរយៈពេល១២សប្តាហ៍បន្តបន្ទាប់ មិនត្រូវលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍

-ថិរវេលាធ្វើការប្រចាំថ្ងៃ មិនត្រូវលើសពីដប់ម៉ោង

-ការពន្យារថិរវេលាធ្វើការមិនត្រូវអោយលើសពីមួយម៉ោងក្នុងមួយថ្ងៃ ។

**ប្រការ៣.-** ក្រៅពីល័ក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ២ខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវ :-

-ពិភាក្សាឯកភាពជាមុន ជាមួយសហជីពដែលមានភាពជាតំណាងនិងជាមួយប្រតិភូបុគ្គលិក ឬចំនួនពាក់កណ្តាលនៃកម្មករនិយោជិតយ៉ាងតិច ចំពោះសហគ្រាស គ្រឹះស្ថានដែលគ្មានប្រតិភូបុគ្គលិកនិងសហជីព

-ធានាការដឹកជញ្ជូនកម្មករនិយោជិតពីលំនៅដ្ឋាន ឬទីជិតខាងនៃលំនៅដ្ឋានរបស់កម្មករនិយោជិតទៅកន្លែងធ្វើការ និងត្រឡប់វិញ បើការធ្វើដំណើររបស់កម្មករនិយោជិតប្រព្រឹត្តទៅនៅពេលយប់

-ប្រើឧបករណ៍ស្វ័យប្រវត្តិដើម្បីចុចសលាកប័ត្រម៉ោងចេញ ចូលធ្វើការរបស់កម្មករនិយោជិតព្រមទាំងរក្សាទុកសលាកប័ត្រនេះរយៈពេលបីឆ្នាំ សំរាប់ការត្រួតពិនិត្យមើលជាយថាហេតុរបស់អធិការការងារ និងតុលាការការងារ ឬតុលាការអាជ្ញាកត្តិ បើមិនទាន់មានតុលាការការងារ

-បិទផ្សាយម៉ោងធ្វើការថ្មីនៅក្នុងសហគ្រាស គ្រឹះស្ថាននិងត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុង នៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសហគ្រាស គ្រឹះស្ថានស្ថិតនៅរាជធានីភ្នំពេញ យ៉ាងហោចណាស់ប្រាំពីរថ្ងៃ មុនការដាក់អោយអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៤.-** ម៉ោងធ្វើការដែលលើសពី ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាតម្លើងដែលបានកំណត់ដោយមាត្រា ១៣៩ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ៨០ សកបយ.ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩០ សកអ.ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា ខេត្ត ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

សាមីសាមីជនពាក់ព័ន្ធ

សាលាពិសេសបងើត

"ដើម្បីជ្រាប"

គ្រប់ទស្សនាវដ្តី និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"

រាជកិច្ច

កាលប្បវត្តិ និងឯកសារ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**